**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**លេខ.** ១៥០/ន.ព ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## អ្នកនាំពាក្យ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

អ្នកនាំពាក្យក្រសួងការពារជាតិ សូមជម្រាបជូនសាធារណជន អំពីការហោះហើរឧទ្ធម្ភាគចក្រយោធា និងការចល័តកម្លាំងទ័ពជើងទឹកនិងគោក កាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ របស់កងយោធពលខេមរភូមិន្ទ នៅលើតំបន់មួយចំនួន ក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល គឺជាការហ្វឹកហ្វឺនសាកល្បង សមត្ថភាពកម្លាំងចល័តរហ័សរបស់ក្រសួងការពារជាតិតែប៉ុណ្ណោះ។

ការហ្វឹកហ្វឺនជាភារកិច្ចចាំបាច់មិនអាចខ្វះបានក្នុងការកសាងកងយោធពលខេមរភូមិន្ទ ដើម្បីពង្រឹងសមត្ថភាពប្រយុទ្ធការពារបូរណភាពទឹកដី ។ ប្រការនេះគួរតែត្រូវបានលើកទឹកចិត្តពីអ្នកនយោបាយដែលមានឆន្ទៈស្នេហាជាតិពិតប្រាកដ ។ អ្នកនយោបាយមួយចំនួនឃើញកងទ័ពប្រឹងប្រែងហ្វឹកហាត់ពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីការពារជាតិមាតុភូមិមិនជួយគាំទ្រលើកទឹកចិត្ត បែរជាចោទថាគំរាមកំហែងនិងបំភិតបំភ័យខ្លួនទៅវិញ ប៉ុន្តែនៅពេលឃោសនាម្តងៗអ្នកនយោបាយទាំងនោះតែងតែអួតក្អេងក្អាងថា ពួកគេគឺជាអ្នកស្នេហាជាតិ និងការពារជាតិ តើពួកគេធ្វើនយោបាយដើម្បីអ្វីនៅពេលដែលឃើញកងទ័ពរបស់ខ្លួនមានការរីកចំរើនបែរជាមិនគាំទ្រទៅវិញ។

អ្នកនាំពាក្យក្រសួងការពារជាតិ សូមច្រានចោលនូវការចោទប្រកាន់ពីអ្នកនយោបាយទាំងនោះ ហើយនិងថ្កោលទោសយ៉ាងម៉ឺងម៉ាត់ចំពោះជនទាំងឡាយណា ដែលមានចេតនាបង្ខូចកិត្តិយសកងយោធពលខេមរភូមិន្ទដែលកំពុងប្រកាន់តួនាទីអព្យាក្រិត្យរបស់ខ្លួន ក្នុងកិច្ចការពារបូរណភាពទឹកដីនិងរាជរដ្ឋាភិបាលស្របច្បាប់ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៦*

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ
c@mod.gov.kh